
បទអន្តរាគមន៍របស់រដ្ឋបាលស្រុកសាមគ្គីមានជ័យ
ស្តីពី
មេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនានា
ពាក់ព័ន្ធនិងកំណែទម្រង់វិមជ្ឈការ និងវិសហម
ជ្ឈការ
ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨


មាតិកា
• ស្ថានភាពមុន និក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហម
ជ្ឈការ
• សមិទ្ធិផលនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
• បញ្ហាប្រឈម
• សំណូមពរ

## ស្ថានភាពមុន និងក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| មុនមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
|---|---|
| **រចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្រុក៖**<br>• រដ្ឋបាលបាលស្រុកមិនមានក្រុមប្រឹក្សាដែលជាតំណាងប្រជាពលរដ្ឋ<br>• រដ្ឋបាលបាលស្រុកជាថ្នាក់រដ្ឋបាលចំណុះឲ្យរដ្ឋបាលខេត្ត<br>• រដ្ឋបាលស្រុកមាន ថ្នាក់ដឹកនាំស្រុក ប្រធានមន្ទីរស្រុក ការិ. រដ្ឋបាលទូទៅ ការិ.សេដ្ឋកិច្ច និងការិ.សង្គមកិច្ច | **រចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្រុក៖**<br>• រដ្ឋបាលស្រុកមានក្រុមប្រឹក្សាស្រុក<br>• រដ្ឋបាលស្រុកជាថ្នាក់រដ្ឋបាលមួយដែលមានក្រុមប្រឹក្សារបស់ខ្លួនដាច់ដោយឡែក<br>• ក្រុមប្រឹក្សាស្រុក៖ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ និង គណៈកម្មាធិការលទ្ធកម្ម<br>• គណៈអភិបាលស្រុក៖ នាយករដ្ឋបាល ការិ.រដ្ឋបាល និងគណនេយ្យ ការិ.អន្តរវិស័យ ការិ. ផែនការ និងគាំទ្រឃុំ និងអង្គភាពលទ្ធកម្ម |

## ស្ថានភាពមុន និងក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| មុនមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
|---|---|
| **សិទ្ធិអំណាចក្នុងការសម្រេចចិត្តលើការគ្រប់គ្រង និងការអភិវឌ្ឍមូលដ្ឋាន៖**<br>• ស្រុកមិនមានសិទ្ធិសម្រេចក្នុងការគ្រប់គ្រងមន្ត្រី បុគ្គលិក<br>• ស្រុកអនុវត្តតាមរយៈបទបញ្ជា និងការណែនាំរបស់ខេត្ត និងក្រសួងមហាផ្ទៃក្នុងការគ្រប់គ្រង ការការពារ និងការអភិវឌ្ឍ<br>• ស្រុកជាអ្នកគាំទ្រ និងសម្របសម្រួល ក្នុងការងារអភិវឌ្ឍមូលដ្ឋានដល់អង្គភាពជំនាញ | **សិទ្ធិអំណាចក្នុងការសម្រេចចិត្តលើការគ្រប់គ្រង និងការអភិវឌ្ឍមូលដ្ឋាន៖**<br>• រដ្ឋបាលស្រុកមានសិទ្ធិអំណាចក្នុងការសម្រេចលើការងាររដ្ឋបាល ការផ្តល់សេវា និងការអភិវឌ្ឍមូល ដ្ឋាន<br>• រដ្ឋបាលស្រុកមានសិទ្ធិសម្រេចលើការគ្រប់គ្រងមន្ត្រី បុគ្គលិក<br>• រដ្ឋបាលស្រុកមានសិទ្ធិអំណាចក្នុងការប្រើប្រាស់ថវិការបស់ខ្លួន និងកៀរគរធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋាន |

## ស្ថានភាពមុន និងក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| មុនមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
|---|---|
| **ធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋាន៖**<br>• ថវិការបស់ស្រុកជាផ្នែកមួយនៃថវិកាខេត្ត<br>• ស្រុកមិនមានកញ្ចប់ថវិកាដោយឡែក សម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍទេ<br>• ស្រុកទទួលបានថវិកាប្រតិបត្តិការ និងសម្ភារៈតិចតួចពីខេត្ត<br>• ស្រុកពុំមានផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់អភិវឌ្ឍន៍មូលដ្ឋាន | **ធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋាន៖**<br>• រដ្ឋបាលស្រុកមានផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ច្បាស់លាស់<br>• រដ្ឋបាលស្រុកមានថវិកាផ្ទាល់ខ្លួនដាច់ដោយឡែកពីរដ្ឋបាលខេត្ត សម្រាប់ចំណាយប្រតិបត្តិការ និងការអភិវឌ្ឍ<br>• រដ្ឋបាលស្រុកទទួលបានការវិភាជន៍ថវិកាប្រចាំឆ្នាំពីថ្នាក់ជាតិសម្រាប់ចំណាយប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវរបស់ប្រជាពលរដ្ឋ |

## ស្ថានភាពមុន និងក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| មុនមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
|---|---|
| **គណនេយ្យភាពរបស់រដ្ឋបាលស្រុក៖**<br>• ស្រុកត្រូវមានគណនេយ្យភាពចំពោះខេត្ត និងថ្នាក់ក្រសួង<br>• ស្រុកគ្រប់គ្រងឃុំ | គណនេយ្យភាពរបស់រដ្ឋបាលស្រុក៖<br>• មានខ្សែគណនេយ្យភាពច្បាស់លាស់ គណៈអភិបាលស្រុកមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុក ហើយក្រុមប្រឹក្សាស្រុកមានគណនេយ្យភាពចំពោះឃុំ និងប្រជាពលរដ្ឋ<br>• ប្រជាពលរដ្ឋមានភាពសកម្មក្នុងការតាមដានសកម្មភាព និងកិច្ចអភិវឌ្ឍមូលដ្ឋានមូលដ្ឋានរបស់ខ្លួន ស្របតាមផែនការយុទ្ធសាស្ត្រគណនេយ្យសង្គម |

## ស្ថានភាពមុន និងក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

| មុនមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ក្រោយមានកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
|---|---|
| ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍមូលដ្ឋាន៖<br>• ការចូលរួមរបស់ប្រជាពលរដ្ឋជាចម្បងគឺការការពារសន្តិសុខ<br>• មានការចូលរួមតិចតួចពីប្រជាពលរដ្ឋក្នុងការអភិវឌ្ឍមូលដ្ឋាន ជាកម្លាំងពលកម្ម ដូចជាជីកប្រឡាយ ការលើកទំនប់ផ្សេងៗ... | ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍមូលដ្ឋាន៖<br>• មានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋក្នុងការកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគដើម្បីអភិវឌ្ឍមូលដ្ឋាន<br>• មានការចូលរួមថវិកាបដិភាគពីប្រជាពលរដ្ឋក្នុងការអភិវឌ្ឍមូលដ្ឋាន |

## សកម្មភាពរបស់រដ្ឋបាលស្រុក



## សកម្មភាពរបស់រដ្ឋបាលស្រុក




សមិទ្ធិផលសំខាន់ៗរបស់រដ្ឋបាលស្រុកក្រោមក្របខណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- រដ្ឋបាលស្រុកមានផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគនិងមូលនិធិរបស់ខ្លួន បានអនុវត្តនូវគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ការផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាសុខភាពអនាម័យ ការផ្សព្វផ្សាយចំណេះដឹងអំពីបញ្ហាយេនឌ័រ ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងគម្រោងផ្តល់សេវាផ្សេងៗទៀត
- លើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅតាមមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- បានពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលស្រុកចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល

## បញ្ហាប្រឈម

- មិនទាន់មានភាពច្បាស់លាស់ក្នុងការបែងចែកមុខងារ និងការទទួលខុសត្រូវក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន
- ធនធានសម្រាប់ការអភិវឌ្ឍមូលដ្ឋានពាក់ព័ន្ធនឹងមុខងារជាអណត្តិទូទៅនៅមានកម្រិតមិនអាចឆ្លើយតប នឹងតម្រូវចាំបាច់របស់ប្រជាពលរដ្ឋ
- រដ្ឋបាលស្រុកមិនទាន់មានចំណូលផ្ទាល់ (សារពើពន្ធ និងមិនមែនសារពើពន្ធ)
- ខ្វះភាពបត់បែនបាននៃនីតិវិធីគ្រប់គ្រង (ហិរញ្ញវត្ថុ និងលទ្ធកម្ម)
- ការគាំទ្របច្ចេកទេសរបស់អង្គភាពជំនាញដល់រដ្ឋបាលស្រុកលើការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវា នៅមានកម្រិត
- រចនាសម្ព័ន្ធគ្រប់គ្រង និងនីតិវិធីការងារនៅរដ្ឋបាលស្រុកពុំទាន់មានលក្ខណៈសមស្របដែលបង្កលក្ខណៈ ងាយស្រួលដល់រដ្ឋបាលស្រុកក្នុងការអនុវត្តមុខងារជាអណត្តិទូទៅរបស់ខ្លួន ដើម្បីផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

## សំណូមពរ

- គួរកំណត់រដ្ឋបាលស្រុកក្លាយជារដ្ឋបាលមូលដ្ឋានស្របតាមគោលការណ៍រដ្ឋបាលឯកភាពដ៏សំខាន់ដែលមានស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តកាន់តែទូលំទូលាយ និងប្រកបដោយការទទួលខុសត្រូវខ្ពស់
- គួរកំណត់ទិសដៅដើម្បីបង្កើនធនធានមនុស្សឱ្យកាន់តែសំបូរបែបប្រកបដោយសមត្ថភាព មានការលើកទឹកចិត្ត និងភាពទាក់ទាញ
- គួរបង្កើនធនធានហិរញ្ញវត្ថុសមស្រប និងមានចំណូលផ្ទាល់សម្រាប់អភិវឌ្ឍមូលដ្ឋាន
- ស្នើឱ្យមានការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលស្រុកកាន់តែច្រើនបន្ថែមទៀតក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវា ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបាលទាន់ពេលវេលា

